ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមហាផ្ទៃ និង
គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
លេខ :....០៣៤...អ.ក.រ

# សេចក្ដីណែនាំរួម
## ស្ដីពី
## នីតិវិធីនៃការស្នើសុំ និងការចេញឯកសារបញ្ជាក់អត្តសញ្ញាណ បម្រើឱ្យការចុះឈ្មោះបោះឆ្នោត និងការបោះឆ្នោត

- យោងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- យោងព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- យោងព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្ដីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- យោងព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- យោងព្រះរាជក្រមលេខ នស/រកម/០៣១៥/០០២ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- យោងព្រះរាជក្រមលេខ នស/រកម/០៣១៥/០០៣ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- យោងព្រះរាជក្រមលេខ នស/រកម/១០១៧/០១០ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- យោងព្រះរាជក្រមលេខ នស/រកម/១២១៥/០១៥ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- យោងព្រះរាជក្រមលេខ នស/រកម/១០១៧/០១២ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់

ក្នុងគោលបំណងធានាសិទ្ធិក្នុងការចុះឈ្មោះបោះឆ្នោត និងការបោះឆ្នោតរបស់ប្រជាពលរដ្ឋខ្មែរ ដែលមិនទាន់មានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ (អ.ខ) ឬ អ.ខ របស់គាត់បានអស់សុពលភាព ឬមិនទាន់ទទួលបាន ឬបាត់ ឬខូច ឬកែតម្រូវ ឱ្យមានភាពងាយស្រួលក្នុងការធ្វើឯកសារបញ្ជាក់អត្តសញ្ញាណ និងដើម្បីឱ្យការចេញឯកសារនេះប្រព្រឹត្តទៅដោយរលូន មានសុក្រឹតភាព គណនេយ្យភាព និងតម្លាភាព ក្រសួងមហាផ្ទៃ និងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) សូមធ្វើការណែនាំអំពីនីតិវិធីសម្រាប់អនុវត្តដូចខាងក្រោម ៖

## I. អំពីឯកសារបញ្ជាក់អត្តសញ្ញាណ

យោងមាត្រា៥១ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ (ច.ប.ត.រ) មេឃុំ ចៅសង្កាត់ ត្រូវបានអនុញ្ញាតឱ្យចេញឯកសារបញ្ជាក់អត្តសញ្ញាណជូនប្រជាពលរដ្ឋតាមការស្នើសុំ ដើម្បីចុះឈ្មោះបោះឆ្នោត ក្នុងករណីដែលអាជ្ញាធរមានសមត្ថកិច្ចមិនអាចផ្តល់ អ.ខ ជូនបានទាន់ពេលវេលា ។

យោងមាត្រា១៦៩ នៃ ច.ប.ត.រ ករណីប្រជាពលរដ្ឋមានឈ្មោះក្នុងបញ្ជីបោះឆ្នោតហើយ ប៉ុន្តែពុំមាន អ.ខ ដើម្បីបោះឆ្នោត អាជ្ញាធរឃុំ សង្កាត់ និងគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត (គឃ.សប) ត្រូវបានអនុញ្ញាតឱ្យចេញឯកសារបញ្ជាក់អត្តសញ្ញាណតាមការស្នើសុំជូនប្រជាពលរដ្ឋ ។

## II. ឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការចុះឈ្មោះបោះឆ្នោត

មេឃុំ ចៅសង្កាត់មានតួនាទី និងភារកិច្ចពិនិត្យលើពាក្យស្នើសុំ លក្ខខណ្ឌ និងសម្រេចចេញឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការចុះឈ្មោះបោះឆ្នោតជូនដល់សាមីអ្នកស្នើសុំ ដែលបានបំពេញត្រឹមត្រូវតាមលក្ខខណ្ឌដូចមានចែងក្នុងសេចក្តីណែនាំរួមនេះ ។

ឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការចុះឈ្មោះបោះឆ្នោតត្រូវផលិតដោយ គ.ជ.ប ជាទម្រង់បោះពុម្ពចងជាសៀវភៅ មានគល់បញ្ជី និងចុងសន្លឹក មានលេខរៀង និងមានចំណុចផ្ទៃកបច្ចេកទេសដើម្បីបង្ការការក្លែងបន្លំ ។

### ១. នីតិវិធីនៃការស្នើសុំឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការចុះឈ្មោះបោះឆ្នោត

#### ក. លក្ខខណ្ឌនៃការស្នើសុំ

ប្រជាពលរដ្ឋដែលស្នើសុំឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការចុះឈ្មោះបោះឆ្នោត ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម ៖

- ស្នើសុំក្នុងអំឡុងពេលចុះឈ្មោះបោះឆ្នោត
- ត្រូវបង្ហាញខ្លួនដោយផ្ទាល់នៅចំពោះមុខមេឃុំ ចៅសង្កាត់ ដែលសាមីខ្លួនកំពុងស្នាក់នៅ និងត្រូវចុះឈ្មោះបោះឆ្នោត
- ត្រូវបង្ហាញសំបុត្រកំណើតច្បាប់ដើម ឬសេចក្តីចម្លងសំបុត្រកំណើត ឬសំបុត្របញ្ជាក់កំណើត ឬសេចក្តីចម្លងសំបុត្របញ្ជាក់កំណើត ឬព្រះរាជក្រឹត្យ ឬសេចក្តីចម្លងព្រះរាជក្រឹត្យផ្តល់សញ្ជាតិខ្មែរ ឬសាលក្រមស្ថាពររបស់តុលាការបញ្ជាក់ទទួលស្គាល់ថាសាមីខ្លួន នោះកើតពីឪពុក ឬម្តាយដែលមានសញ្ជាតិខ្មែរ
- នាំមកនូវសាក្សី ២ (ពីរ) រូប
- យកមកនូវរូបថតរបស់សាមីខ្លួន ទំហំ ៣ x ៤ ចំនួន ២ (ពីរ) សន្លឹក ថតចំពីមុខដែលបង្ហាញមុខ និងស្មា និងដែលអាចបញ្ជាក់អត្តសញ្ញាណរបស់សាមីអ្នកស្នើសុំបានត្រឹមត្រូវ និងច្បាស់លាស់ ។ រូបថតនេះ សម្រាប់បិទនៅផ្នែកខាងលើចំហៀងខាងស្តាំនៃគល់បញ្ជី និងចុងសន្លឹកនៃឯកសារបញ្ជាក់អត្តសញ្ញាណ
- ត្រូវបំពេញពាក្យស្នើសុំឯកសារបញ្ជាក់អត្តសញ្ញាណ ហើយត្រូវផ្តិតស្នាមម្រាមដៃនៅចំពោះមុខមេឃុំ ចៅសង្កាត់ ។

**ខ-លក្ខណសម្បត្តិរបស់សាក្សី**

សាក្សីត្រូវមានលក្ខណសម្បត្តិ និងបំពេញលក្ខខណ្ឌដូចខាងក្រោម ៖

- មានសិទ្ធិបោះឆ្នោត និងមានលំនៅឋាន ឬទីសំណាក់ក្នុងឃុំ សង្កាត់ជាមួយអ្នកស្នើសុំ
- ផ្តិតស្នាមម្រាមដៃធានាអះអាងលើពាក្យស្នើសុំឯកសារបញ្ជាក់អត្តសញ្ញាណ នៅចំពោះមុខមេឃុំ ចៅសង្កាត់
- មិនមែនជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ មេឃុំ ចៅសង្កាត់ ជំទប់ ចៅសង្កាត់រង ឬស្មៀនឃុំ សង្កាត់ ។

(ទម្រង់ពាក្យស្នើសុំឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការចុះឈ្មោះបោះឆ្នោត មាននៅឧបសម្ព័ន្ធទី១)

**២. របៀបបទ និងនីតិវិធីក្នុងការចេញឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការចុះឈ្មោះបោះឆ្នោត**

មេឃុំ ចៅសង្កាត់មានសមត្ថកិច្ចក្នុងការចេញឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការចុះឈ្មោះបោះឆ្នោតជូនប្រជាពលរដ្ឋក្នុងឃុំ សង្កាត់របស់ខ្លួនតាមការស្នើសុំ ដោយមិនតម្រូវឱ្យបង់ថ្លៃឡើយ ។ របៀបបទ និងនីតិវិធីក្នុងការចេញលិខិតបញ្ជាក់អត្តសញ្ញាណត្រូវអនុវត្តដូចខាងក្រោម ៖

- បំពេញទម្រង់ឯកសារបញ្ជាក់អត្តសញ្ញាណ
- ចុះហត្ថលេខា កាលបរិច្ឆេទ និងបោះត្រាឃុំ សង្កាត់នៅលើហត្ថលេខារបស់ខ្លួន
- បោះត្រានៅផ្នែកពាក់កណ្តាលខាងក្រោមនៃរូបថតរបស់អ្នកស្នើសុំ នៅលើគល់បញ្ជី និងចុងសន្លឹកនៃទម្រង់ និងបោះត្រាបន្ថែមនៅចំពាក់កណ្តាលរវាងគល់បញ្ជី និងចុងសន្លឹកនៃទម្រង់
- ហែកផ្តាច់ចុងសន្លឹកពីគល់បញ្ជីនៃទម្រង់ រួចប្រគល់ចុងសន្លឹកនៃទម្រង់ជូនអ្នកស្នើសុំ ដោយរក្សាទុកគល់បញ្ជីក្នុងសៀវភៅបញ្ជីនៃទម្រង់ជាឯកសាររបស់ឃុំ សង្កាត់ ។

ក្នុងករណីអ្នកស្នើសុំឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការចុះឈ្មោះបោះឆ្នោត ពុំបានបំពេញលក្ខខណ្ឌ ឬប្រសិនបើអ្នកស្នើសុំ និងសាក្សីពុំបានផ្តល់ព័ត៌មាន និងការធានាអះអាងគ្រប់គ្រាន់ និងត្រឹមត្រូវដូចចែងក្នុងចំណុច ១ នៃចំណុច II ខាងលើ មេឃុំ ចៅសង្កាត់ត្រូវណែនាំអ្នកស្នើសុំឱ្យបំពេញលក្ខខណ្ឌ និងព័ត៌មានឱ្យបានគ្រប់គ្រាន់ និងត្រឹមត្រូវ ដើម្បីធ្វើការស្នើសុំជាថ្មី ។

មេឃុំ ចៅសង្កាត់ត្រូវយកចិត្តទុកដាក់បំពេញទម្រង់ឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការចុះឈ្មោះបោះឆ្នោត ឱ្យបានច្បាស់លាស់ និងត្រឹមត្រូវ ។ ក្នុងករណីបំពេញខុស និងមិនអាចចេញឱ្យប្រើបាន មេឃុំ ចៅសង្កាត់ត្រូវគូសខ្វែងលើគល់បញ្ជី និងចុងសន្លឹកនៃទម្រង់ និងរក្សាទុកទាំងគល់បញ្ជី និងចុងសន្លឹកដែលខុសនោះនៅក្នុងសៀវភៅបញ្ជីឱ្យបានល្អ និងមានសុវត្ថិភាពនៅសាលាឃុំ សង្កាត់ ។

**៣. ទម្រង់ និងទិន្នន័យក្នុងឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការចុះឈ្មោះបោះឆ្នោត**

ឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការចុះឈ្មោះបោះឆ្នោត ត្រូវមានទម្រង់ និងទិន្នន័យដូចខាងក្រោម ៖

- ក្រដាសពណ៌ស មានគល់បញ្ជី និងចុងសន្លឹក ១ (មួយ)
- ការយោងពាក្យស្នើសុំរបស់សាមីខ្លួន ដែលមានស្នាមម្រាមដៃរបស់អ្នកស្នើសុំ និងសាក្សីទាំងពីររូប
- រូបថតសាមីខ្លួន
- នាមត្រកូល នាមខ្លួន ភេទ ថ្ងៃ ខែ ឆ្នាំកំណើត សញ្ជាតិខ្មែរ លំនៅឋាន ឬទីសំណាក់ក្នុងឃុំ សង្កាត់
- ហត្ថលេខារបស់មេឃុំ ចៅសង្កាត់ និងត្រា ។

(ទម្រង់ឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការចុះឈ្មោះបោះឆ្នោត មាននៅឧបសម្ព័ន្ធទី២)

៤. ករណីបាត់ ឬខូចឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការចុះឈ្មោះបោះឆ្នោត

ក្នុងករណីបាត់ ឬខូចឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការចុះឈ្មោះបោះឆ្នោត ការស្នើសុំជាថ្មី ត្រូវអនុវត្តតាមនីតិវិធីនៃការស្នើសុំដូចមានចែងក្នុងចំណុច ១ ព្រមទាំងបែបបទ និងនីតិវិធីដូចមានចែងក្នុងចំណុច ២ នៃចំណុច II ខាងលើ ហើយមេឃុំ ចៅសង្កាត់ត្រូវសរសេរបញ្ជាក់ពាក្យថា "ចេញជាលើកទី២" នៅខាងចុងចំណងជើងទាំងគល់បញ្ជី ទាំងចុងសន្លឹក ។

### III. ឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោត

គឃ.សប មានតួនាទី និងភារកិច្ចពិនិត្យលើពាក្យស្នើសុំ លក្ខខណ្ឌ និងសម្រេចចេញឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោតជូនដល់សាមីអ្នកស្នើសុំ ដែលបានបំពេញត្រឹមត្រូវតាមលក្ខខណ្ឌដូចមានចែងក្នុងសេចក្តីណែនាំរូមនេះ ។ រដ្ឋបាលឃុំ សង្កាត់ មានតួនាទីពិនិត្យ និងចុះហត្ថលេខាផ្តល់សុពលភាពលើឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោត ។

ឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោត ត្រូវបោះពុម្ពចេញពីប្រព័ន្ធកុំព្យូទ័រដោយ គឃ.សប ដោយទាញយកទិន្នន័យសំខាន់ៗដែលអាចសម្គាល់បានពីអត្តសញ្ញាណរបស់អ្នកស្នើសុំ និង អ.ខ ឬឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការចុះឈ្មោះបោះឆ្នោត ដែលបានប្រើក្នុងការចុះឈ្មោះបោះឆ្នោត ។ គ.ជ.ប ត្រូវផ្គត់ផ្គង់សម្ភារ បរិក្ខារកុំព្យូទ័រ និងសម្ភារចាំបាច់នានាផ្សេងទៀតដល់ គឃ.សប សម្រាប់បម្រើឱ្យការចេញឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោតនេះ ជូនអ្នកបោះឆ្នោត ។

១. នីតិវិធីនៃការស្នើសុំឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោត

ដើម្បីស្នើសុំឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោត អ្នកបោះឆ្នោតត្រូវបំពេញលក្ខខណ្ឌ ដូចខាងក្រោម ៖

- ស្នើសុំក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ មុនថ្ងៃបោះឆ្នោត និងត្រូវបញ្ឈប់ត្រឹម ១ (មួយ) ថ្ងៃ មុនថ្ងៃបោះឆ្នោតនីមួយៗ វេលាម៉ោង ៥.៣០ នាទីល្ងាច ជាកំហិត
- ត្រូវបង្ហាញខ្លួនដោយផ្ទាល់ នៅចំពោះមុខ គឃ.សប នៃឃុំ សង្កាត់ដែលសាមីខ្លួនមានឈ្មោះក្នុងបញ្ជីបោះឆ្នោតផ្លូវការ និងត្រូវបោះឆ្នោត
- ត្រូវបំពេញពាក្យស្នើសុំ និងត្រូវផ្តិតស្នាមម្រាមដៃនៅចំពោះមុខប្រធាន គឃ.សប
- ផ្តល់ស្នាមម្រាមដៃតាមការណែនាំរបស់សមាជិក គឃ.សប ទទួលបន្ទុករដ្ឋបាល និងថតរូបសម្រាប់ការផ្ទៀងផ្ទាត់ និងទាញទិន្នន័យពីបញ្ជីបោះឆ្នោតផ្លូវការ ក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោត ។

(ទម្រង់ពាក្យស្នើសុំឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោត មាននៅឧបសម្ព័ន្ធទី៣)

២. បែបបទ និងនីតិវិធីនៃការចេញឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោត

ប្រធាន គឃ.សប មានសមត្ថកិច្ចក្នុងការពិនិត្យ និងសម្រេចចេញឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោត ជូនអ្នកបោះឆ្នោតតាមការស្នើសុំដោយមិនតម្រូវឱ្យបង់ថ្លៃឡើយ ។ បែបបទ និងនីតិវិធីនៃការចេញឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោត មានដូចខាងក្រោម ៖

- យកស្នាមម្រាមដៃសាមីខ្លួន ឬស្វែងរកឈ្មោះតាមរយៈលេខ អ.ខ ឬតាមនាមត្រកូល ឬនាមខ្លួនសម្រាប់ជនមានពិការភាព ឬអ្នកបោះឆ្នោតដែលខូចខ្នាដៃ ដើម្បីពិនិត្យផ្ទៀងផ្ទាត់ភាពត្រឹមត្រូវបន្ថែមទៀតរវាងពាក្យស្នើសុំជាមួយទិន្នន័យក្នុងបញ្ជីបោះឆ្នោតផ្លូវការ ដោយត្រូវយកចិត្តទុកដាក់ជាសំខាន់ទៅលើនាមត្រកូល និងនាមខ្លួន ភេទ ថ្ងៃ ខែ ឆ្នាំកំណើត ប្រភេទ អ.ខ ឬឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការចុះឈ្មោះបោះឆ្នោត ដែលបានប្រើក្នុងការចុះឈ្មោះបោះឆ្នោត ព្រមទាំងរូបថតរបស់សាមីខ្លួន ដោយប្រៀបធៀបរវាងរូបថត និងរូបពិត,

- ត្រូវបោះពុម្ពទម្រង់ឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោត ចេញពីប្រព័ន្ធគ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោត ប្រសិនបើអ្នកបោះឆ្នោតបានបំពេញលក្ខខណ្ឌត្រឹមត្រូវ
- ចុះហត្ថលេខា និងបោះត្រា គឃ.សប លើហត្ថលេខារបស់ខ្លួន និងបោះត្រាបន្ថែមនៅចំពាក់កណ្ដាលរវាងផ្នែកទាំង ២ (ពីរ) នៃទម្រង់
- ចាត់ឱ្យសមាជិកទទួលបន្ទុករដ្ឋបាលស្កេនពាក្យស្នើសុំ ព្រមទាំងទម្រង់ឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោត (ទាំង ២ (ពីរ) ផ្ទាំង) បញ្ចូលក្នុងប្រព័ន្ធកុំព្យូទ័រ ដើម្បីរក្សាទុកជាឯកសារនៅ គឃ.សប
- ជម្រាបអ្នកស្នើសុំ ឱ្យយកទម្រង់ឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោតនេះ ទៅជួបមេឃុំ ចៅសង្កាត់ ដើម្បីចុះហត្ថលេខា និងបោះត្រាផ្ដល់សុពលភាពប្រើប្រាស់ជាផ្លូវការ ។

ក្នុងករណីអ្នកស្នើសុំពុំបានបំពេញត្រឹមត្រូវតាមលក្ខខណ្ឌដូចមានចែងក្នុងចំណុច ១ នៃចំណុច III នៃសេចក្ដីណែនាំរួមនេះទេ ប្រធាន គឃ.សប ត្រូវណែនាំអ្នកស្នើសុំឱ្យបំពេញលក្ខខណ្ឌ និងព័ត៌មាន ឱ្យបានគ្រប់គ្រាន់ និងត្រឹមត្រូវ ដើម្បីធ្វើការស្នើសុំជាថ្មី ។

ក្នុងករណីប្រធាន គឃ.សប បោះពុម្ពទម្រង់ឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោតខុស ឬចុះហត្ថលេខា ឬបោះត្រាលើទម្រង់ឯកសារបញ្ជាក់អត្តសញ្ញាណមិនបានត្រឹមត្រូវតាមការណែនាំខាងលើទេ ប្រធាន គឃ.សប ត្រូវគូសខ្វែងលើទម្រង់ ឯ.អ ។ គឃ.សប ត្រូវរក្សាទុកទម្រង់ឯកសារបញ្ជាក់អត្តសញ្ញាណដែលគូសខ្វែងនោះឱ្យបានល្អ និងមានសុវត្ថិភាពនៅទីស្នាក់ការ គឃ.សប ។

មេឃុំ ចៅសង្កាត់មានសមត្ថកិច្ចក្នុងការពិនិត្យ និងសម្រេចផ្ដល់សុពលភាពលើទម្រង់ឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោត សម្រាប់ប្រើជាផ្លូវការ ។ បន្ទាប់ពីមេឃុំ ចៅសង្កាត់ចុះហត្ថលេខារួចហើយ ត្រូវចាត់ស្មៀនឃុំ សង្កាត់ឱ្យបោះត្រាលើហត្ថលេខារបស់មេឃុំ ចៅសង្កាត់ រួចហែកផ្ដាច់ទម្រង់ឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោតជា ២ (ពីរ) សន្លឹក រួចប្រគល់ ១ (មួយ) សន្លឹក ជូនអ្នកស្នើសុំ និងរក្សា ១ (មួយ) សន្លឹក ទុកជាឯកសារនៅសាលាឃុំ សង្កាត់ ។

**៣. ទម្រង់ និងទិន្នន័យក្នុងឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោត**

ឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោតត្រូវបានបោះពុម្ពចេញពីប្រព័ន្ធកុំព្យូទ័រ លើក្រដាសពណ៌សខ្នាត A4 ក្នុងទម្រង់ជាក្រដាស ២ (ពីរ) ផ្ទាំង អាចហែកផ្ដាច់បាន និងមានទិន្នន័យដូចខាងក្រោម ៖

- លេខកូដសម្ងាត់ ( QR Code) ដើម្បីបង្ការការក្លែងបន្លំឯកសារ
- ការយោងពាក្យស្នើសុំ ដែលមានស្នាមម្រាមដៃរបស់សាមីខ្លួន
- ការបញ្ជាក់ពីទិន្នន័យក្នុងបញ្ជីបោះឆ្នោតដូចជា នាមត្រកូល និងនាមខ្លួន ភេទ ថ្ងៃ ខែ ឆ្នាំកំណើត លេខរៀងក្នុងបញ្ជី លេខ អ.ឧ ឬឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការចុះឈ្មោះបោះឆ្នោត អត្តលេខ ឯកសារចុះឈ្មោះ លេខកូដ និងទីតាំងការិយាល័យបោះឆ្នោត រូបថត អ.ឧ ឬឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការចុះឈ្មោះបោះឆ្នោត និងរូបថតសាមីខ្លួនពេលចុះឈ្មោះបោះឆ្នោត
- សុពលភាពប្រើប្រាស់

- ហត្ថលេខារបស់ប្រធាន គឃ.សប និងត្រា គឃ.សប បញ្ជាក់អំពីភាពត្រឹមត្រូវនៃទិន្នន័យរបស់អ្នកស្នើសុំ
- ហត្ថលេខារបស់មេឃុំ ចៅសង្កាត់ និងត្រាឃុំ សង្កាត់ បញ្ជាក់អំពីការផ្ដល់សុពលភាព ។

(ទម្រង់ឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោត មាននៅឧបសម្ព័ន្ធទី៤)

**៤-ករណីបាត់ ឬខូចឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោត**

ក្នុងករណីបាត់ ឬខូចឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោត ការស្នើសុំជាថ្មីត្រូវអនុវត្តតាមនីតិវិធីនៃការស្នើសុំដូចមានចែងក្នុងចំណុច ១ ព្រមទាំងបែបបទ និងនីតិវិធីដូចមានចែងក្នុងចំណុច ២ នៃចំណុច III ខាងលើ ដោយប្រធាន គឃ.សប ត្រូវសរសេរបញ្ជាក់ពាក្យថា "ចេញជាលើកទី២" នៅខាងចុងចំណាងជើងនៃទម្រង់ឯកសារបញ្ជាក់អត្តសញ្ញាណទាំងពីរផ្នែក ។

## IV. ការរក្សាសៀវភៅបញ្ជីឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការចុះឈ្មោះបោះឆ្នោត និងទម្រង់ឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោត

**១. ការរក្សាសៀវភៅបញ្ជីឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោត**

មេឃុំ ចៅសង្កាត់ត្រូវរក្សាទុកសៀវភៅបញ្ជីឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការចុះឈ្មោះបោះឆ្នោតឱ្យបានល្អ និងប្រកបដោយសុវត្ថិភាពនៅសាលាឃុំ សង្កាត់ ។ សៀវភៅបញ្ជីឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការចុះឈ្មោះបោះឆ្នោតដែលត្រូវរក្សាទុកមាន ៖

សៀវភៅបញ្ជីឯកសារបញ្ជាក់អត្តសញ្ញាណដែលពុំទាន់បានប្រើ
- សៀវភៅបញ្ជីឯកសារបញ្ជាក់អត្តសញ្ញាណដែលបានប្រើខ្លះហើយ
- សៀវភៅបញ្ជីឯកសារបញ្ជាក់អត្តសញ្ញាណដែលប្រើអស់ហើយ និងនៅសល់តែគល់បញ្ជី គិតទាំងសន្លឹកទម្រង់ដែលបំពេញខុសផង (ប្រសិនបើមាន) ។

**២. ការរក្សាទម្រង់ឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោត**

ប្រធាន គឃ.សប ត្រូវចាត់ចែងរក្សាទុកទម្រង់ឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោតដែលសមាជិកទទួលបន្ទុករដ្ឋបាលបានស្កេន នៅក្នុងប្រព័ន្ធកុំព្យូទ័រ ។ មេឃុំ ចៅសង្កាត់ត្រូវរក្សាទុកទម្រង់ឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោត ដែលស្មៀនបានហែកផ្ដាច់ឱ្យបានល្អ និងប្រកបដោយសុវត្ថិភាពនៅសាលាឃុំ សង្កាត់ ។

## V. ការធ្វើរបាយការណ៍បូកសរុបអំពីការចេញឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការចុះឈ្មោះបោះឆ្នោត និងបោះឆ្នោត

**១. ការធ្វើរបាយការណ៍អំពីការចេញឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការចុះឈ្មោះបោះឆ្នោត**

នៅពេលបញ្ចប់ការចុះឈ្មោះបោះឆ្នោតនៅក្នុងឃុំ សង្កាត់របស់ខ្លួន មេឃុំ ចៅសង្កាត់ត្រូវធ្វើរបាយការណ៍ចំនួន ៣ (បី) ច្បាប់ ដោយត្រូវចុះហត្ថលេខា កាលបរិច្ឆេទ និងបោះត្រាឃុំ សង្កាត់ដើម្បី ៖

- បិទផ្សាយជាសាធារណៈភ្លាមៗនៅសាលាឃុំ សង្កាត់ ១ (មួយ) ច្បាប់
- រក្សាទុកជាឯកសារ ១ (មួយ) ច្បាប់
- ផ្ញើជូនលេខាធិការដ្ឋានរាជធានី ខេត្តរៀបចំការបោះឆ្នោត (លធ.ខប) ជាបន្ទាន់ ស្របពេលជាមួយនឹងការបញ្ជូនសម្ភារៈ បរិក្ខារ និងឯកសារចុះឈ្មោះបោះឆ្នោត ។

ចំពោះ គធ.ឧប បន្ទាប់ពីទទួលបានរបាយការណ៍ពីឃុំ សង្កាត់ ត្រូវធ្វើការបូកសរុបរបាយការណ៍នៅក្នុងរាជធានី ខេត្តរបស់ខ្លួន ដើម្បីផ្ញើជូន គ.ជ.ប ជាបន្ទាន់ និងថតចម្លងជូនក្រសួងមហាផ្ទៃ ស្របពេលជាមួយគ្នានឹងការបញ្ជូនសម្ភារ បរិក្ខារ និងឯកសារចុះឈ្មោះបោះឆ្នោតទៅ គ.ជ.ប ។

**២. ការធ្វើរបាយការណ៍អំពីការចេញឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោត**

បន្ទាប់ពីបញ្ចប់ការចេញឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោតនៅ ១ (មួយ) ថ្ងៃមុនថ្ងៃបោះឆ្នោត ប្រធាន គឃ.សប ត្រូវធ្វើរបាយការណ៍ចំនួន ៤ (បួន) ច្បាប់ ដោយត្រូវចុះហត្ថលេខា កាលបរិច្ឆេទ និងបោះត្រា គឃ.សប ដើម្បី៖

- បិទផ្សាយជាសាធារណៈភ្លាមៗនៅទីស្នាក់ការ គឃ.សប ១ (មួយ) ច្បាប់
- ផ្ញើជូនរដ្ឋបាលឃុំ សង្កាត់ ១ (មួយ) ច្បាប់
- រក្សាទុកជាឯកសារ ១ (មួយ) ច្បាប់
- ផ្ញើជូនគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត (គធ.ឧប) ចំនួន ១ (មួយ) ច្បាប់
- ស្កេនរបាយការណ៍នេះបញ្ជូនទៅ គ.ជ.ប តាមប្រព័ន្ធអ៊ីនធឺណិត ។

ចំពោះរបាយការណ៍ដែលត្រូវផ្ញើជូន គធ.ឧប គឃ.សប ត្រូវផ្ញើជូនស្របពេលនឹងការបញ្ជូនសម្ភារ បរិក្ខារ និងឯកសារបោះឆ្នោត ដោយត្រូវបោះពុម្ពទម្រង់ឯកសារបញ្ជាក់អត្តសញ្ញាណដែលបានស្កេនបញ្ចូលក្នុងប្រព័ន្ធកុំព្យូទ័រភ្ជាប់មកជាមួយផង ។ បន្ទាប់ពីទទួលបានរបាយការណ៍ពី គឃ.សប ហើយ គធ.ឧប ត្រូវធ្វើការបូកសរុបរបាយការណ៍ក្នុងរាជធានី ខេត្តរបស់ខ្លួនចំនួន ៥ (ប្រាំ) ច្បាប់ រួចបិទផ្សាយជាសាធារណៈនៅ គធ.ឧប ១ (មួយ) ច្បាប់ ផ្ញើជូនគណៈអភិបាលរាជធានី ខេត្តពាក់ព័ន្ធ ១ (មួយ) ច្បាប់ រក្សាទុកជាឯកសារនៅ គធ.ឧប ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ និងចម្លងជូនក្រសួងមហាផ្ទៃ ១ (មួយ) ច្បាប់ ស្របពេលនឹងការបញ្ជូនសម្ភារ បរិក្ខារ និងឯកសារបោះឆ្នោត ដោយត្រូវភ្ជាប់របាយការណ៍របស់ គឃ.សប និងទម្រង់ឯកសារបញ្ជាក់អត្តសញ្ញាណដែល គឃ.សប បានបោះពុម្ពចេញពីប្រព័ន្ធកុំព្យូទ័រមកជាមួយផង ។

**VI. សុពលភាពប្រើប្រាស់ឯកសារបញ្ជាក់អត្តសញ្ញាណ និងទណ្ឌកម្ម**

បែបបទ និងនីតិវិធីនៃការស្នើសុំ និងការចេញឯកសារបញ្ជាក់អត្តសញ្ញាណដូចមានចែងក្នុងចំណុច II និងចំណុច III នៃសេចក្តីណែនាំនេះ មានវិសាលភាពអនុវត្តជាទូទៅសម្រាប់គ្រប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។

ឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការចុះឈ្មោះបោះឆ្នោត មានសុពលភាពប្រើសម្រាប់តែការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតនៃឆ្នាំនីមួយៗប៉ុណ្ណោះ ។ ឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោត មានសុពលភាពប្រើសម្រាប់តែថ្ងៃបោះឆ្នោតប៉ុណ្ណោះ ។

ឯកសារបញ្ជាក់អត្តសញ្ញាណដែលថតចម្លង កែ កោស ឬលុប មិនអាចប្រើប្រាស់ជាផ្លូវការបានឡើយ ។

គឃ.សប និងរដ្ឋបាលឃុំ សង្កាត់ ឬជនណាម្នាក់ ដែលក្លែងបន្លំឯកសារបញ្ជាក់អត្តសញ្ញាណ ឬចេញឯកសារបញ្ជាក់អត្តសញ្ញាណមិនបានត្រឹមត្រូវតាមបែបបទ និងនីតិវិធី ឬបង្ការអុកឡុក រំខានដល់ដំណើរការចេញឯកសារបញ្ជាក់អត្តសញ្ញាណ ឬមិនព្រមចេញឯកសារបញ្ជាក់អត្តសញ្ញាណជូនអ្នកស្នើសុំដែលបំពេញគ្រប់លក្ខខណ្ឌតាមសេចក្តីណែនាំនេះ ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន ។

## VII. ការផ្សព្វផ្សាយជាសាធារណៈ

រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ គធ.ឃប/លធ.ឃប ត្រូវចូលរួមសហការដើម្បីផ្សព្វផ្សាយសេចក្តីណែនាំរួមនេះ ឱ្យបានទូលំទូលាយក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

សេចក្តីណែនាំរួមនេះ ជំនួសឱ្យសេចក្តីណែនាំរួមលេខ ០១៨ សណន ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៦ រវាងក្រសួងមហាផ្ទៃ និង គ.ជ.ប ស្តីពីនីតិវិធីនៃការស្នើសុំ និងការចេញឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការចុះឈ្មោះបោះឆ្នោត និងការបោះឆ្នោត ។

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន គ.ជ.ប អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល អគ្គនាយកនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្មនៃក្រសួងមហាផ្ទៃ ប្រធានក្រុមប្រឹក្សា និងអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ប្រធានក្រុមប្រឹក្សា និងអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ មេឃុំ ចៅសង្កាត់ ស្មៀនឃុំ សង្កាត់ មេភូមិ ប្រធាន គធ.ឃប/លធ.ឃប និងប្រធាន គឃ.សប ត្រូវយកចិត្តទុកដាក់អនុវត្តសេចក្តីណែនាំរួមនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃព្រហស្បតិ៍ ១២រោច ខែទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែសីហា ឆ្នាំ២០២១

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** **គ.ណ.កម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រធាន**

**សម្តេចក្រឡាហោម ស ខេង** **ប្រាជ្ញ ចន្ទ**

**<u>កន្លែងទទួល៖</u>**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យ **សម្តេចក្រឡាហោម**
- អគ្គលេខាធិការដ្ឋាន គ.ជ.ប
- អគ្គនាយកដ្ឋានរដ្ឋបាលនៃក្រសួងមហាផ្ទៃ
- អគ្គនាយកដ្ឋានអត្តសញ្ញាណកម្មនៃក្រសួងមហាផ្ទៃ
- រដ្ឋបាលថ្នាក់ក្រោមជាតិ
- លេខាធិការដ្ឋានរាជធានី ខេត្តរៀបចំការបោះឆ្នោត
- គណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធទី១

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

## ពាក្យស្នើសុំ

## ឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការចុះឈ្មោះបោះឆ្នោត

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ ..............................ភេទ.........សញ្ជាតិ.........កើតនៅថ្ងៃទី.........ខែ.........ឆ្នាំ.................. មានលំនៅឋាន ឬទីសំណាក់លេខ.............ផ្លូវ.............ភូមិ...........................ឃុំ សង្កាត់............................... ក្រុង ស្រុក ខណ្ឌ...........................រាជធានី ខេត្ត...........................។

## របនឹងសាក្សី

ឈ្មោះ....................................ភេទ.........សញ្ជាតិ...........កើតនៅថ្ងៃទី.........ខែ...........ឆ្នាំ.................និង

ឈ្មោះ....................................ភេទ.........សញ្ជាតិ...........កើតនៅថ្ងៃទី.........ខែ...........ឆ្នាំ........................

ដែលមានសិទ្ធិបោះឆ្នោត និងមានលំនៅឋាន ឬទីសំណាក់ក្នុងឃុំ សង្កាត់ជាមួយ ដែលធានាថា ពិតជាស្គាល់ ខ្ញុំបាទ/នាងខ្ញុំ ប្រាកដមែន និងទទួលខុសត្រូវតាមច្បាប់ជាធរមាន ចំពោះការធានានេះ ។

## គោរពជូន

លោក លោកស្រីមេឃុំ ចៅសង្កាត់...............................

កម្មវត្ថុ ៖ សំណើសុំឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការចុះឈ្មោះបោះឆ្នោត ។

សេចក្ដីដូចបានជម្រាបជូនខាងលើ ខ្ញុំបាទ/នាងខ្ញុំ សូមជម្រាប លោក លោកស្រីមេឃុំ ចៅសង្កាត់ ថានៅពេលចុះឈ្មោះបោះឆ្នោត ខ្ញុំបាទ/នាងខ្ញុំមិនទាន់មានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ☐ ឬអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែររបស់ ខ្ញុំបាទ/នាងខ្ញុំ បានអស់សុពលភាព ឬមិនទាន់ទទួលបាន ☐ ឬបានបាត់ ឬខូច ឬកែតម្រូវ ☐ ។

អាស្រ័យហេតុនេះសូមលោក លោកស្រីមេឃុំ ចៅសង្កាត់ចេញឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការចុះឈ្មោះបោះឆ្នោតឱ្យ ខ្ញុំបាទ/នាងខ្ញុំ ដោយអនុគ្រោះ ។

............ថ្ងៃទី............ខែ............ឆ្នាំ............

| ស្នាមម្រាមដៃសាក្សីទី១ | ស្នាមម្រាមដៃសាក្សីទី២ | ស្នាមម្រាមដៃអ្នកស្នើសុំ |
|---|---|---|
| | | |
| ឈ្មោះ............................ | ឈ្មោះ............................ | ឈ្មោះ............................ |

**ចំណាំ ៖** - ត្រូវបង្ហាញជូនលោកលោកស្រីមេឃុំ ចៅសង្កាត់នូវ សំបុត្រកំណើតច្បាប់ដើម ឬសេចក្ដីចម្លងសំបុត្រកំណើត ឬសំបុត្របញ្ជាក់កំណើត ឬសេចក្ដីចម្លងសំបុត្របញ្ជាក់កំណើត ឬព្រះរាជក្រឹត្យ ឬសេចក្ដីចម្លងព្រះរាជក្រឹត្យផ្ដល់សញ្ជាតិខ្មែរ ឬសាលក្រមស្ថាពររបស់តុលាការបញ្ជាក់ទទួលស្គាល់ថាសាមីខ្លួននោះកើតពីឪពុក ឬម្ដាយដែលមានសញ្ជាតិខ្មែរ ។

- ត្រូវផ្ដិតមេដៃនៅមុខមេឃុំ ចៅសង្កាត់ ។

ឧបសម្ព័ន្ធទី២

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

№ XXXXXXX

រាជធានី ខេត្ត____________
ក្រុង ស្រុក ខណ្ឌ____________
ឃុំ សង្កាត់____________
លេខ ____________

**ឯកសារបញ្ជាក់អត្តសញ្ញាណ**
**បម្រើឱ្យការចុះឈ្មោះបោះឆ្នោត**

រូបថត
៣x៤

យោងពាក្យស្នើសុំរបស់សាមីខ្លួនចុះថ្ងៃទី____________ខែ__________ឆ្នាំ____________
យើងមេឃុំ ចៅសង្កាត់ ☐ ជំទប់/ចៅសង្កាត់រងទទួលសិទ្ធិ ☐ ____________________
ចេញឯកសារបញ្ជាក់អត្តសញ្ញាណឱ្យឈ្មោះ____________________ភេទ________សញ្ជាតិ______
កើតនៅថ្ងៃទី________ខែ________ឆ្នាំ________មានលំនៅឋាន ឬទីសំណាក់លេខ______ផ្លូវ______ភូមិ
______________ក្នុងឃុំ សង្កាត់នេះ ប្រើប្រាស់សម្រាប់បម្រើឱ្យការចុះឈ្មោះបោះឆ្នោតតែប៉ុណ្ណោះ។

__________ថ្ងៃទី______ខែ______ឆ្នាំ______
ហត្ថលេខា ឈ្មោះ និងត្រាឃុំ សង្កាត់


**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

№ XXXXXXX

រាជធានី ខេត្ត____________
ក្រុង ស្រុក ខណ្ឌ____________
ឃុំ សង្កាត់____________
លេខ ____________

**ឯកសារបញ្ជាក់អត្តសញ្ញាណ**
**បម្រើឱ្យការចុះឈ្មោះបោះឆ្នោត**

រូបថត
៣x៤

យោងពាក្យស្នើសុំរបស់សាមីខ្លួនចុះថ្ងៃទី____________ខែ__________ឆ្នាំ____________
យើងមេឃុំ ចៅសង្កាត់ ☐ ជំទប់/ចៅសង្កាត់រងទទួលសិទ្ធិ ☐ ____________________
ចេញឯកសារបញ្ជាក់អត្តសញ្ញាណឱ្យឈ្មោះ____________________ភេទ________សញ្ជាតិ______
កើតនៅថ្ងៃទី________ខែ________ឆ្នាំ________មានលំនៅឋាន ឬទីសំណាក់លេខ______ផ្លូវ______ភូមិ
______________ក្នុងឃុំ សង្កាត់នេះ ប្រើប្រាស់សម្រាប់បម្រើឱ្យការចុះឈ្មោះបោះឆ្នោតតែប៉ុណ្ណោះ។

__________ថ្ងៃទី______ខែ______ឆ្នាំ______
ហត្ថលេខា ឈ្មោះ និងត្រាឃុំ សង្កាត់